# មេរៀនទី ១៤៣: យ៉ូសាផាតទុកចិត្តព្រះដើម្បីជ័យជំនះ

## ២ របាក្សត្រ ២០:១-៣០

**គោលបំណង៖** ព្រះជួយដល់យើងពេលយើងជួបបញ្ហា។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១២១:២** *"សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

យើងដែលជាអ្នកដើរតាមព្រះគ្រីស្ទ ជារាស្ត្រនៃនគរដ៏អស្ចារ្យរបស់ទ្រង់។ ពេលយើងប្រឈមមុខនឹងការលំបាក ព្រះយេស៊ូវនៅក្បែរយើង។ ទ្រង់ប្រទានឲ្យយើងនូវប្រាជ្ញា និងយុទ្ធសាស្ត្រដែលនាំទៅរកជ័យជម្នះ និងសន្តិភាព អានការអធិស្ឋានរបស់យ៉ូសាផាតឡើងវិញនៅក្នុង **២ របាក្សត្រ២០:៦-១២**។ សូមកត់សម្គាល់ថាគាត់ប្រកាសពីអំណាច និងពីកិច្ចការរបស់ព្រះហើយទទួលស្គាល់ថាគាត់ពឹងផ្អែកលើព្រះ។ សូមពិចារណាអំពីសមរភូមិក្នុងជីវិតរបស់អ្នក ហើយសរសេរការអធិស្ឋានស្រដៀងគ្នានៃការសរសើរ និងការទទួចអង្វរទៅកាន់ព្រះ។

**ចំរៀង៖** ១. One Way ២. ខ្ញុំរត់ពីព្រះជាម្ចាស់មិនបាន ៣. ហូសាណា

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «រើសសំរាម!»**

**សម្ភារៈដែលត្រូវការ៖** ធុងសំរាម ថង់ប្លាស្ទិក (ក្រដាសខ្ទិកខ្ទក ដបទឹកទទេ និងរបស់ផ្សេងៗទៀត)



១. ទុកសំរាមនៅគ្រប់កន្លែងផ្សេងៗនៅក្នុងថ្នាក់រៀន។

២. ចែកកុមារជា ២ក្រុម។

៣. សុំឱ្យក្រុមនីមួយៗបញ្ជូនអ្នកតំណាងម្នាក់។ ប្រាប់អ្នកតំណាងទាំង ២នាក់ ឱ្យរើសសំរាមឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដោយប្រើតែដៃម្ខាងតែប៉ុណ្ណោះ។ កុមារដែលរើសសំរាមបានច្រើនជាគេនឹងឈ្នះល្បែងនេះ។

៤. បន្ទាប់មកអនុញ្ញាតឱ្យក្រុមបញ្ជូនអ្នកតំណាងម្នាក់ទៀតមកជួយ។ ឥឡូវនេះកុមារ ២នាក់មកពីក្រុមនីមួយៗ អាចរើសសំរាមបានច្រើនតាមតែអាចធ្វើទៅបានដោយគ្រាន់តែប្រើតែដៃម្ខាងតែប៉ុណ្ណោះ។ ក្រុមដែលមានសំរាមច្រើននឹងឈ្នះការប្រកួតនេះ។



៥.បន្ទាប់មកអនុញ្ញាតឱ្យអ្នកផ្សេងចូលរួមក្នុងក្រុមរើសសំរាម។ លើកនេះឲ្យថង់ប្លាស្ទិកទៅគេ។ ប៉ុន្តែពួកគេនៅតែអាចប្រើបានតែដៃម្ខាងតែប៉ុណ្ណោះ។ ក្រុមដែលមានសំរាមច្រើនឈ្នះការប្រកួត។

(គន្លឹះ៖កុំប្រាប់កុមារថាមនុស្សពីរនាក់អាចជួយកាន់ថង់ដោយដៃម្ខាងរបស់ពួកគេ ហើយអ្នកទីបីរើសសំរាមដើម្បីដាក់ក្នុងថង់។)

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពេលយើងត្រូវការជំនួយក្នុងជីវិតព្រះតែងតែជួយយើង។

## ៤. ការណែនាំមេរៀន

តើអ្នកនឹងធ្វើដូចម្ដេច ប្រសិនបើអ្នកឮថាមានកងទ័ពធំមកបំផ្លាញអ្នក? តើអ្នកនឹងលាក់ខ្លួននៅក្នុងផ្ទះរបស់អ្នកឬ? តើអ្នកនឹងរត់គេចឬ? តើអ្នកនឹងសុំជំនួយពីឪពុកម្ដាយរបស់អ្នកឬ? ថ្ងៃនេះយើងនឹងរៀនអំពីបុរសម្នាក់ ដែលមានកងទ័ពដ៏ធំចូលមកបំផ្លាញគាត់ និងប្រទេសរបស់គាត់។ តោះមកដឹងពីអ្វីដែលគាត់បានធ្វើ ដើម្បីជំនះបញ្ហានោះ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីររបស់យើងប្រាប់យើងអំពីបុរសម្នាក់ឈ្មោះ យ៉ូសាផាត។ ទ្រង់ជាស្ដេចនៃរាជាណាចក្រយូដា។ យ៉ូសាផាតស្រឡាញ់ព្រះ ហើយបានជួយរាស្ត្រទ្រង់បម្រើព្រះ។ នៅថ្ងៃមួយ យ៉ូសាផាតបានដឹងថា កងទ័ពដ៏ធំមួយកំពុងមកបំផ្លាញលោក។ តើអ្នកនឹងធ្វើដូចម្ដេច ពេលអ្នកដឹងថាមានកងទ័ពដ៏ធំមួយកំពុងមកបំផ្លាញអ្នកនោះ? ទោះជាគាត់មានទ័ពធំក៏ដោយ ក៏យ៉ូសាផាតមិនបានប្រមូលទ័ពរបស់គាត់សម្រាប់ចំបាំងដ៏ធំនេះដែរ។

យ៉ូសាផាតបានដឹងថាព្រះនឹងជួយគាត់ ដូច្នេះគាត់បានអធិស្ឋានទៅព្រះ។ មនុស្សគ្រប់គ្នាបានចូលរួមដើម្បីអធិស្ឋានជាមួយគាត់ផងដែរ។ ពួកគេទាំងអស់គ្នាបានតមអាហារ។ នោះមានន័យថាពួកគេមិនញ៉ាំអីទេ។ ពួកគេបានចំណាយពេលអធិស្ឋានជំនួសវិញ។ ពេលនោះមានបុរសម្នាក់ជាមនុស្សរបស់ព្រះក្រោកឡើង ហើយនិយាយថា៖ **២ របាក្សត្រ ២០:១៥,១៧** “កុំឲ្យភ័យខ្លាចអ្វីឡើយ ក៏កុំឲ្យស្រយុតចិត្ត ដោយព្រោះពួកកងទ័ពធំទាំងនេះដែរ ដ្បិតចំបាំងនេះមិនមែនស្រេចនៅអ្នករាល់គ្នាទេ គឺស្រេចនៅព្រះវិញ... ចូរនៅកន្លែងរបស់អ្នក...”។ “ចូរនៅកន្លែងរបស់អ្នក” មានន័យថាឈរនៅកន្លែងត្រឹមត្រូវសម្រាប់ការប្រយុទ្ធ។

យ៉ូសាផាតបានស្ដាប់បង្គាប់។ គាត់បានសុំឱ្យអ្នកចំរៀងច្រៀងសរសើរតម្កើងព្រះជាម្ចាស់។ បន្ទាប់មកខ្មាំងសត្រូវចាប់ផ្ដើមវាយគ្នាទៅវិញទៅមក ជាជាងច្បាំងនឹងទ័ពរបស់យ៉ូសាផាត! កងទ័ពរបស់យ៉ូសាផាតមិនចាំបាច់ច្បាំងទាល់តែសោះ ដូចព្រះបានមានបន្ទូល! ព្រះបានសង្គ្រោះយ៉ូសាផាត និងរាស្ត្ររបស់ទ្រង់ពីទុក្ខលំបាករបស់ពួកគេ!

ដូចគ្នាដែរ ព្រះតែងតែចង់ជួយពេលយើងមានបញ្ហា។ ព្រះយកចិត្តទុកដាក់ចំពោះបញ្ហានីមួយៗដែលយើងមាន។ ព្រះយកចិត្តទុកដាក់ពេលយើងភ័យខ្លាច ហើយទ្រង់លួងលោមយើង។ ព្រះយកចិត្តទុកដាក់នៅពេលដែលយើងវង្វេង ហើយទ្រង់ផ្ដល់ប្រាជ្ញានិងការយល់ដឹង។ មិនថាបញ្ហារបស់យើងធំឬតូចប៉ុណ្ណានោះទេ យើងអាចជឿជាក់បានថា ព្រះមិនត្រឹមតែយកព្រះទ័យទុកដាក់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់នឹងផ្ដល់ជំនួយដ៏ត្រឹមត្រូវ ដើម្បីឲ្យយើងឆ្លងកាត់វាបាន។ យើងមានព្រះដ៏អស្ចារ្យដែលតែងតែជួយយើង!

## ៦. សំនួរពិភាក្សា

១. តើរឿងក្នុងព្រះគម្ពីររបស់យើងថ្ងៃនេះស្ដេចយូដាមានឈ្មោះអ្វី? *យ៉ូសាផាត*

២. តើគាត់បានធ្វើអ្វីពេលគាត់ឮថាមានកងទ័ពដ៏ធំមួយកំពុងមកបំផ្លាញស្រុកយូដា?
*គាត់បានអធិស្ឋានសុំជំនួយពីព្រះ*

៣. តើព្រះបានជួយយ៉ូសាផាតឲ្យឈ្នះការច្បាំងយ៉ាងណា ពេលគាត់ស្ដាប់បង្គាប់ព្រះ?

*ពួកខ្មាំង សត្រូវវាយគ្នាឯងជំនួសឲ្យការវាយទ័ពរបស់យ៉ូសាផាត*

៤. តើអ្នកអាចធ្វើអ្វីបាននៅពេលអ្នកមានបញ្ហា ឬជួបទុក្ខលំបាក? *អ្នកអាចសុំជំនួយពីព្រះ*

## ៧. ល្បែងកំសាន្ត «ព្រះជួយយើង»




១. ជ្រើសរើសកុមារ ២នាក់ ដែលម្នាក់ដើរតួជា “បញ្ហា” និងម្នាក់ទៀតជា “អ្នកជួយ”។

២. កុមារដែលនៅសល់ត្រូវតែរត់ចេញពី “បញ្ហា” ហើយ “បញ្ហា” ត្រូវតែព្យាយាមទៅប៉ះកុមារទាំងអស់នោះ។

៣. នៅពេលដែល “បញ្ហា” ប៉ះកុមារបាន ពួកគេត្រូវតែឈប់ទ្រឹងមួយកន្លែង។ បន្ទាប់មកពួកគេអាចសុំឱ្យ “អ្នកជួយ”មកជួយប៉ះពួកគេដើម្បីឲ្យពួកគេអាចរត់បន្តបាន។

៤. “អ្នកជួយ”ត្រូវតែរត់ជុំវិញដើម្បីស្វែងរកអ្នកដែលស្កុបមួយកន្លែង ហើយប៉ះពួកគេដើម្បីឲ្យពួកគេរត់បន្តវិញ។

៥. បន្ទាប់ពីលេងល្បែងនេះបានប្រហែល ៥នាទី សូមជ្រើសរើសកុមារ ២នាក់ទៀតដើម្បីធ្វើជា “អ្នកជួយ”។ វិធីនេះមិនថា “បញ្ហា” ធ្វើឲ្យកុមារស្កុបច្រើនប៉ុណ្ណាក៏ដោយក៏មាន “អ្នកជួយ” ជាច្រើនបន្ថែមទៀត ដើម្បីជួយកុមារដែលឈប់ទ្រឹងទាំងនោះបាន។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ទោះបីជាបញ្ហាធំប៉ុណ្ណាក៏ដោយ ព្រះរបស់យើងធំជាងហើយតែងតែជួយយើងពីបញ្ហារបស់យើងនោះ។

## ៨. ខគម្ពីរចងចាំ ទំនុកដំកើង ១២១:២

## ៩. ហត្ថកម្ម ផាត់ពណ៌រូបភាពរបស់យ៉ូសាផាត

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# យ៉ូសាផាតទុកចិត្តព្រះដើម្បីជ័យជំនះ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________________

______________________________________________________

______________________________________________________

______________________________________________________